ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២២២ សហវ.ប្រក

រាជធានីភ្នំពេញថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០០៥

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មាធិការសីលធម៌វិជ្ជាជីវៈ ប្រចាំវិទ្យាស្ថានគណនេយ្យករជំនាញ និង សវនករកម្ពុជា

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ

-បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ/បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសមាសភាពនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ **ក.ជ.គ**

-បានឃើញអនុក្រឹត្យលេខ ១៨/អនក្រ/បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា **វ.គ.ស.ក**

-បានឃើញប្រកាសលេខ ២៤៦ សហវ. ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៣ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលប្រចាំវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា

-បានឃើញកំណត់ហេតុប្រជុំថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៤ របស់ក្រុមប្រឹក្សាភិបាលប្រចាំ **វ.គ.ស.ក**

-បានឃើញការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សំរេច

**ប្រការ ១** : តែងតាំង :

| | | |
|---|---|---|
| ១-លោក **ឈិន គុសល** | តំណាងក្រសួងយុត្តិធម៌ | ប្រធាន |
| ២-លោក **គុយ លីម** | អនុប្រធាន ក.ជ.គ អាណត្តិទី ១ | អនុប្រធាន |
| ៣-ឯកឧត្តម **ទី តាយី** | អនុរដ្ឋលេខាធិការនិងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ | សមាជិក |
| ៤-លោកស្រី **ជុំ វ៉ានី** | អនុប្រធានក្រុមប្រឹក្សាភិបាល វ.គ.ស.ក អាណត្តិទី ១ | សមាជិក |
| ៥-លោក **មាស សក្តិសម** | តំណាងក្រុមហ៊ុនឯកជន | សមាជិក |
| ៦-លោក **ម៉ូ ថាវិន** | មន្ត្រីក្រុមប្រឹក្សាជាតិគណនេយ្យ | សមាជិកអចិន្ត្រៃយ៍និងជាលេខាធិការ |

ជាគណៈកម្មាធិការសីលធម៌វិជ្ជាជីវៈ ប្រចាំវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ។

**ប្រការ ២** : គណៈកម្មាធិការសីលធម៌វិជ្ជាជីវៈ មានភារកិច្ចទទួលនិងដោះស្រាយពាក្យបណ្តឹង ដែលទទួលបានពី :

-ក្រុមប្រឹក្សាភិបាលវិទ្យាស្ថាន ចំពោះបណ្តឹងទាំងឡាយណាដែលបានដាក់ដោយតតិយជនពាក់ព័ន្ធដល់សមាជិកវិទ្យាស្ថាន

-សមាជិកវិទ្យាស្ថានរូបណាមួយ ដើម្បីដោះស្រាយវិវាទរវាងសមាជិកផងគ្នា

-ទាយាទនៃសមាជិកស្លាប់ណាម្នាក់ ដែលបានប្តឹងអោយដោះស្រាយបញ្ហាគ្រប់គ្រងបណ្តោះអាសន្នលើអតិថិជនរបស់សមាជិកដែលបានស្លាប់ទៅនោះ

-ស្ថាប័ននៃរាជរដ្ឋាភិបាល ក្នុងករណីដែលសមាជិកវិទ្យាស្ថានណាមួយ មិនគោរពតាមក្រមសីលធម៌ដែលបានកំណត់សិទ្ធិនិងកាតព្វកិច្ចរបស់សមាជិករូបនោះ ។

**ប្រការ ៣** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អង្គភាពពាក់ព័ន្ធ ព្រមទាំងសាម៉ីជន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារៈកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

ចម្លងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួង/ស្ថាប័នពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៣
-ឯកសារ/កាលប្បវត្តិ